FARMER NOTES
ព្រឹត្តិប័ត្រព័ត៌មានកសិករ
ឆ្នាំទី ៩ លេខ ៩៣ ខែកុម្ភៈ ឆ្នាំ២០១០
ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ការទុកដាក់ស្រូវ

**ការ**ទុកដាក់ស្រូវឲ្យមានសុវត្ថិភាព ជាកិច្ចការសំខាន់មួយក្នុងចំណោមកិច្ចប្រត្តិបត្តក្រោយពេលប្រមូលផល។ គ្រាប់ស្រូវអាចទទួលរងការខូចខាតបរិមាណ និងគុណភាព បើសិនយើងមិនយកចិត្តទុកដាក់លើបរិក្ខា និងប្រព័ន្ធទុកដាក់នោះទេ។ ជាទូទៅ ការទុកដាក់ត្រូវបានចែកចេញជាពីរធំៗគឺ បែបបិទជិត និងចំហរ។ បរិក្ខាសម្រាប់ទុកដាក់ស្រូវមានច្រើនទម្រង់ ឬប្រភេទ អាស្រ័យទៅតាមប្រភេទស្រូវ (ពូជ ឬចំណី) ដែលត្រូវទុកដាក់ គោលបំណង និងទីកន្លែង។ ជាទូទៅចំពោះស្រូវចំណី គួរតែទុកដាក់ក្នុងទម្រង់ជាគ្រាប់ស្រូវប្រសើរជាងអង្ករ ដោយសារសំបកស្រូវ (អង្កាម) អាចការពារប្រឆាំងពីការបំផ្លាញរបស់សត្វល្អិត និងជួយការពារពីការខូចគុណភាព។

## ការទុកដាក់បិទជិត



**ប្រព័ន្ធ**ទុកដាក់បិទជិត ដែលមានដូចជា ធុងជ័រ ដែក ឬច្រកក្នុងថង់ស្វិត ដោយបិទមាត់ជិត អាចកាត់បន្ថយការបាត់បង់បរិមាណ និងគុណភាព ថែរក្សាអត្រាសំណើមដើមរបស់គ្រាប់ស្រូវ មិនឲ្យប្រែប្រួល ទប់ស្កាត់ការបំផ្លាញពីសត្វល្អិតចង្រៃដោយមិនប្រើថ្នាំគីមី តាមរយៈការថយចុះនូវកម្រិតអុកស៊ីសែន រហូតដល់ ១០ ដល់ ១៥ ភាគរយ រក្សាដំណុះគ្រាប់ពូជឲ្យនៅខ្ពស់រហូតដល់ ៨ ទៅ ១០ ខែ (ខ្ពស់ជាង ១៩ ភាគរយ ធៀបនិងការទុកដាក់ធម្មតា) ការទុកដាក់របៀបនេះក៏អាចរក្សា គុណភាព ពិសេសពណ៌ ក្លិន និងរស់ជាតិពេលចម្អិន។



ដើម្បីទុកដាក់ស្រូវតាមវិធីសាស្ត្របែបនេះឲ្យមានសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ ត្រូវសម្អាត និងសម្ងួតគ្រាប់ស្រូវ (ពូជ ១២ ភាគរយ និងចំណី ១៤ ភាគរយ) ដោយច្រកក្នុងធុងជ័រ ឬថង់ផ្លាស្ទិក ដោយចងមាត់ថង់ឲ្យជិតរួចដាក់ក្នុងការ៉ុងមួយជាន់ទៀត ចំពោះធុងគួប្រើខ្លាញ់គោ លាបគម្របមុនពេលបិទភ្ជិត និងធ្វើការលាងសម្អាតធុងដោយប្រុងប្រយ័ត្នមុននិងយកទៅប្រើប្រាស់ម្តងទៀត។

## តើការទុកដាក់ដោយចំហរអាចកើតមានបញ្ហាអ្វីខ្លះ?

**បើ**យើងទុកដាក់ស្រូវក្នុងជង្រុកមិនសមស្រប មិនមានប្រព័ន្ធការពារពីសត្វកកេរ និងសត្វស្លាប ឬបាំងការពារទឹកភ្លៀងនោះទេ សំណើមគ្រាប់ស្រូវអាចមានការប្រែប្រួលឡើងចុះ អាស្រ័យសំណើមបរិយាកាស ធ្វើឲ្យកើតមានផ្សិត និងវត្តមានសត្វល្អិតចង្រៃ ពិសេសប្រភេទខ្មូត ដែលជាហេតុបង្ករឲ្យខូចគុណភាពគ្រាប់ ជាពិសេសដំណុះគ្រាប់ពូជ និងថយចុះយ៉ាងឆាប់រហ័ស សម្រាប់ស្រូវចំណីធ្វើឲ្យអត្រាអង្ករដើមតិចជាង ១០ ភាគរយ ធៀបនិងទុកដាក់បិទជិត ហើយគ្រាប់អង្ករមានពណ៌ស្អាប់ ក្លិនមិនល្អ និងបាត់បង់រស់ជាតិ ។ ការទុកដាក់បែបនេះអាច ទទួល រងនូវកត្តាចង្រៃផ្សេងៗទៀតដូចជា លាមកសត្វ ទឹកនោម និងរោមសត្វដែលអាច បង្ករជាមេរោគសម្រាប់អ្នកប្រើប្រាស់។



## ហេតុអ្វីបានជាការគ្រប់គ្រងសត្វចង្រៃមានសារៈសំខាន់?

**សេចក្តី**ត្រូវការរបស់អតិថិជន គឺគ្រាប់ស្រូវស្អាត គ្មានសត្វល្អិត និងគ្មានសំណល់សារធាតុគីមី ដូច្នេះការគ្រប់គ្រងសត្វល្អិត

ក្នុងកំឡុងពេលទុកដាក់គឺជាការសំខាន់ ហើយគួរតែធ្វើតាមរបៀបចម្រុះ និងដោយយកចិត្តទុកដាក់ ដើម្បីថែរក្សាបរិមាណ និងគុណភាពគ្រាប់ស្រូវឲ្យបានយូរ ទាំងការបរិភោគ និងលក់ចេញបានតម្លៃថ្លៃ។ ដើម្បីគ្រប់គ្រងសត្វល្អិតប្រកបដោយប្រសិទ្ធភាព រួមមាន៖ ត្រូវអនុវត្តតាមបច្ចេកទេសសមស្រប ទាំងការប្រមូលផល ការសម្ងួតមុនពេលទុកដាក់ស្រូវ រៀបចំសម្ភារៈបរិក្ខាទុកដាក់ ជាពិសេសគួរធ្វើការកែលម្អរជង្រុក ដោយធ្វើយ៉ាងណាចៀសវាងការធ្វើឲ្យស្រូវសើមឡើងវិញ ដោយទឹកភ្លៀង ដាក់សំណាញ់ជុំវិញការពារកណ្តុរ និងសត្វស្លាប កែសម្រួលជើងជង្រុក ត្រួតពិនិត្យ និងការពារកុំឲ្យពពួកសត្វល្អិតកើតមានក្នុងពេលទុកដាក់។



## ការបំផ្លាញរបស់សត្វកណ្តុរ

**កណ្តុរ**ប្រែងពេញវ័យមួយក្បាលស៊ីស្រូវប្រហែល ២៥ ក្រាម ហើយកណ្តុរតូចៗប្រហែលជា ៣ ទៅ ៤ ក្រាម ក្នុងមួយថ្ងៃ។ ពួកវាធ្វើឲ្យប្រឡាក់គ្រាប់ស្រូវដែលរក្សាទុក តាមរយៈទឹកនោម លាមក រោម និងភ្នាក់ងារបង្កពាគផ្សេងៗទៀតជាច្រើន។ នៅពេលដែលគ្រាប់ស្រូវរងឥទ្ធិពលអាក្រក់ពីពពួកសត្វកកេរទាំងនោះ វាបណ្តាលឲ្យខូចទាំងគុណភាព និងបាត់បង់ទាំងបរិមាណ ជាពិសេសគុណភាពដំណុះធ្លាក់ចុះ សម្រាប់ស្រូវពូជ និងបាត់បង់រស់ជាតិសម្រាប់ស្រូវចំណី ជាងនេះទៅទៀត កណ្តុលចម្លងជំងឺប្រហែល ៥០ ប្រភេទ ទៅលើមនុស្ស ដូចជាជំងឺគ្រុនពោះវៀន ជំងឺកមរមាស់ គ្រុនក្តៅ ។ល។ ម្យ៉ាងទៀតវាក៏ជាភ្នាក់ងារចម្លងជំងឺមួយ ដែលជះឥទ្ធិពលអាក្រក់ទៅលើពពួកសត្វស្រុក។



## លក្ខខណ្ឌទុកដាក់ផលិតផលអោយមានសុវត្ថិភាព

**រយៈ**ពេលទុកដាក់កាន់តែយូរ អត្រាសំណើមគ្រាប់សម្រាប់ការទុកដាក់សុវត្ថិភាពកាន់តែទាប។ ស្រូវចំណី និងស្រូវពូជដែលទុកដាក់ក្នុងអត្រាសំណើមខ្ពស់ជាង ១៤ ភាគរយ បណ្តាលឲ្យកើតមានការដុះផ្សិត និងធ្វើឲ្យគុណភាពបាត់បង់យ៉ាងឆាប់រហ័ស ជាពិសេសដំណុះរបស់គ្រាប់ស្រូវពូជ និងបាត់បង់រសជាតិ។

*តារាងខាងក្រោមបង្ហាញពីអត្រាសំណើមសុវត្ថិភាពសម្រាប់ទុកដាក់ផលិតផលផ្សេងៗ*

| ផលិតផល | អត្រាសំណើមសុវត្ថិភាព (%) | ផលិតផល | អត្រាសំណើមសុវត្ថិភាព (%) |
|---|---|---|---|
| ពោត | ១៣ | សណ្តែក | ១៥ |
| ស្រូវសាលី | ១៣ | សណ្តែកដី | ៧ |
| ស្រូវ | ១៤ | កាកាវ | ៧ |
| អង្ករ | ១៣ | កាហ្វេ | ១៣ |

លក្ខខណ្ឌដ៏ល្អបំផុតសម្រាប់ការកើតមានសត្វល្អិតគឺនៅសីតុណ្ហភាពពី ២៨ ទៅ ៣៣ អង្សាសេ និងសំណើមធៀបពី ៦០ ទៅ ៨០ ភាគរយ ជាមួយគ្នានេះដែរវាក៏បង្កើតចំនួនកូនចៅបានច្រើនណាស់ដែរ។

*តារាងខាងក្រោមបង្ហាញពីអត្រាសំណើមសុវត្ថិភាពសម្រាប់ការទុកដាក់ស្រូវ*

| រយៈពេលទុកដាក់ | អត្រាសំណើមសុវត្ថិភាព | បញ្ហាអាចកើតមាន |
|---|---|---|
| ២-៣ អាទិត្យ | ១៤-១៨ % | ផ្សិត ប្រែពណ៌ បាត់បង់ដំណកដង្ហើម |
| ៨-១២ ខែ | ១២-១៣ % | សត្វល្អិតបំផ្លាញ |
| លើសពី ១ ឆ្នាំ | ៩ % ឬទាបជាង | បាត់បង់គុណភាព (ដំណុះទាប) |

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យវិស្វកម្មកសិកម្ម មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh
ទូរអក្សរ: sbunna@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh